ឃ- តម្លើងឋានន្តរសក្តិ ថ្នាក់ឧត្តមសេនីយ៍ត្រី

-វរសេនីយ៍ឯក ឡោក ឆាយ អត្តលេខ ០០៣៦១២ ជំនួយការផ្ទាល់ សម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា

មាត្រា ២.- នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឲ្យបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣.- ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០០

ព្រះហស្តលេខា

**នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

បានជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី

សហរដ្ឋម ន្ត្រីក្រសួងការពារជាតិ

ព្រះហស្តលេខា និង ហត្ថលេខា

អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ សិរីរ័ត្ន ទៀ បាញ់

***

## II- រាជរដ្ឋាភិបាល

### ១- អនុក្រឹត្យ

**អនុក្រឹត្យលេខ ៨៥ អនក្រ .បក**

**ស្តីពី**

**ការបង្កើតមហាវិទ្យាល័យគ្រប់គ្រងនីតិសាស្ត្រ**

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង នាយករដ្ឋម ន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៥ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី

- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ១៩៩២ ស្តីពីការបង្កើត និង គ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និង សិក្សាឯកទេស
- តាមសំណើរបស់ក្រសួងអប់រំ យុវជន និងកីឡា

**សំរេច**

មាត្រា ១.- អនុញ្ញាតឲ្យបង្កើតមហាវិទ្យាល័យឯកជនមួយ ដែលមានឈ្មោះថា មហាវិទ្យាល័យគ្រប់គ្រង និង នីតិសាស្ត្រ **(Faculty of Management and Law)** ហៅកាត់ថា "ម .គ.ន" ។ មហាវិទ្យាល័យនេះ មានទីតាំងនៅ អាគារលេខ ៩៩ស ផ្លូវលេខ ២០៥ សង្កាត់ទួលស្វាយព្រៃទី ២ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ ។

មាត្រា ២.- មហាវិទ្យាល័យគ្រប់គ្រង និងនីតិសាស្ត្រ ធ្វើការបណ្តុះបណ្តាលថ្នាក់បរិញ្ញាប័ត្រដែលមានរយៈពេលសិក្សា ៤ឆ្នាំ ។

មាត្រា ៣.- មហាវិទ្យាល័យគ្រប់គ្រង និង នីតិសាស្ត្រ មានមហាវិទ្យាល័យ ពីរ :

-មហាវិទ្យាល័យគ្រប់គ្រង

-មហាវិទ្យាល័យនីតិសាស្ត្រ

ក្នុងពេលអនាគត មហាវិទ្យាល័យនេះ អាចបើកវគ្គបណ្តុះបណ្តាលជំនាញរយៈពេលខ្លី និង ជំនាញឯកទេសផ្សេងៗទៀត ក្នុងវិស័យ គ្រប់គ្រង និង នីតិសាស្ត្រ ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាតពីក្រសួង អប់រំ យុវជន និងកីឡា ។

មាត្រា ៤.- លក្ខខ័ណ្ឌទទួលសិស្សឲ្យចូលរៀន :

-បេក្ខជនទាំងពីរភេទ ជាសិស្ស និស្សិត ប្រជាពលរដ្ឋ និងមន្ត្រីរាជការ

-បេក្ខជនត្រូវមានសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ រឺ សញ្ញាប័ត្រដែលមានតំលៃស្មើ

-បេក្ខជនត្រូវឆ្លងកាត់ការប្រលងតេស្ត ។

មាត្រា ៥.- នាយក មហាវិទ្យាល័យគ្រប់គ្រង និង នីតិសាស្ត្រ មានភារកិច្ច :

-ជ្រើសរើស សិស្សឲ្យចូលរៀន និងជ្រើសរើស សាស្ត្រាចារ្យមកបង្រៀន

-គ្រប់គ្រងឲ្យបានល្អ នូវការបង្រៀន ការងារស្រាវជ្រាវ ឯកសារសិក្សា ការប្រលង និងការប្រគល់សញ្ញាប័ត្រ

-គោរព និង អនុវត្ត តាមសារាចរ និង សេចក្តីណែនាំ របស់រាជរដ្ឋាភិបាល

-ធានាឲ្យបាន នូវសុវត្ថិភាព និង សណ្តាប់ធ្នាប់សង្គម

-ធ្វើរបាយការណ៍ របស់សកម្មភាពសិក្សា ជូនក្រសួងអប់រំ យុវជន និងកីឡា ប្រចាំឆមាសនីមួយៗ ។

មាត្រា ៦.- មហាវិទ្យាល័យនេះមានក្រុមប្រឹក្សាភិបាលមួយ ទទួលបន្ទុកក្នុងការគ្រប់គ្រង មហាវិទ្យាល័យ ។

មាត្រា ៧.- នៅក្នុងមហាវិទ្យាល័យនេះ មានក្រុមប្រឹក្សាវិទ្យាសាស្ត្រមួយ ដែលមានសមាជិកយ៉ាងតិច ៣នាក់ ដែលមានសញ្ញាប័ត្រម៉ាស្ទ័រយ៉ាងទាប ក្នុងមុខជំនាញ របស់មហាវិទ្យាល័យសំរាប់ពិនិត្យ និង ផ្តល់ការយល់ព្រម លើកម្មវិធីសិក្សា នៅដើមឆ្នាំសិក្សានីមួយៗ ។

មាត្រា ៨.- ក្រសួងអប់រំ យុវជន និងកីឡា មានសិទ្ធិធ្វើ អធិការកិច្ច និងត្រួតពិនិត្យ លើការងារបណ្តុះបណ្តាល ហើយមានសិទ្ធិស្នើសុំបិទ ប្រសិនបើមហាវិទ្យាល័យនេះ អនុវត្តខុសពីច្បាប់រដ្ឋ ។

មាត្រា ៩.- និស្សិត ដែលរៀនចប់ កម្មវិធីសិក្សា របស់មហាវិទ្យាល័យនេះ និង បានទទួលជោគជ័យក្នុងការប្រឡងបញ្ចប់ការសិក្សា ត្រូវបានទទួលសញ្ញាប័ត្រថ្នាក់បរិញ្ញាប័ត្រ ដែលផ្តល់ឲ្យដោយមហាវិទ្យាល័យគ្រប់គ្រង និងនីតិសាស្ត្រ ហើយត្រូវបានទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា ដោយអនុវត្តតាមនិយាមអប្បបរិមា នៃការទទួលស្គាល់គុណភាពបណ្តុះបណ្តាលកំរិតឧត្តមសិក្សា ។

មាត្រា ១០.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា អគ្គនាយកដ្ឋាន អង្គភាពពាក់ព័ន្ធ និងមហាវិទ្យាល័យគ្រប់គ្រង និង នីតិសាស្ត្រ មានភារកិច្ចរៀងៗខ្លួន ដើម្បីអនុវត្ត និងប្រតិបត្តិ តាមអនុក្រឹត្យនេះ ។

មាត្រា ១១.- អនុក្រឹត្យនេះមាន ប្រសិទ្ធភាព និង គតិយុត្តិ ចាប់ពីថ្ងៃចុះ ហត្ថលេខានេះតទៅ ។

ភ្នំពេញ ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

**អនុក្រឹត្យលេខ ៤៦ អនក្រ .បក**

**ស្តីពី**

**ការកែប្រែរចនាសម្ព័ន្ធ នៃមហាវិទ្យាល័យ ន័រតុន**

**ទៅជាសកលវិទ្យាល័យ ន័រតុន**

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា